**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៩៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការចេញផ្សាយធនប័ត្រ ប្រភេទ ១០០០ រៀល គំរូថ្មី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- តាមសំណើរបស់អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

## ស ម្រេ ច

**មាត្រា ១.-** អនុញ្ញាតឲ្យចេញផ្សាយ ធ្វើចរាចរ និងប្រើប្រាស់ក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា នូវធនប័ត្រ ប្រភេទ ១០០០ រៀល គំរូថ្មី ទន្ទឹមនឹងបណ្តាប្រភេទប្រាក់ដែលត្រូវបានចេញផ្សាយរួចហើយ ។

**មាត្រា ២.-** ធនាគារជាតិនៃកម្ពុជាមានភារកិច្ចចេញសេចក្តីប្រកាស ដើម្បីផ្សព្វផ្សាយពីលក្ខណៈសម្គាល់នៃធនប័ត្រ ប្រភេទ ១០០០ រៀល គំរូថ្មី នេះ ។

**មាត្រា ៣.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន និងអភិបាលរាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ តុលា ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៨៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការចេញផ្សាយធនប័ត្រ ប្រភេទ ៥000 រៀល គំរូថ្មី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- តាមសំណើរបស់អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

## ស ម្រេ ច

**មាត្រា ១.-** អនុញ្ញាតឲ្យចេញផ្សាយ ធ្វើចរាចរ និងប្រើប្រាស់ក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា នូវធនប័ត្រ ប្រភេទ ៥០០០ រៀល គំរូថ្មី ទន្ទឹមនឹងបណ្តាប្រភេទប្រាក់ដែលត្រូវបានចេញផ្សាយរួចហើយ ។

**មាត្រា ២.-** ធនាគារជាតិនៃកម្ពុជាមានភារកិច្ចចេញសេចក្តីប្រកាស ដើម្បីផ្សព្វផ្សាយពីលក្ខណៈសម្គាល់នៃធនប័ត្រ ប្រភេទ ៥០០០ រៀល គំរូថ្មី នេះ ។

**មាត្រា ៣.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន និងអភិបាលរាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ តុលា ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧.០១៧-៣២៣ ប្រ.ក

# ប្រកាស
# ស្តីពី
# លក្ខណៈសម្គាល់នៃធនប័ត្រ ប្រភេទ ១០០០ រៀល គំរូថ្មី

***********

អនុលោមតាមអនុក្រឹត្យលេខ ១៨៣ អនក្រ.បក របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ២៥ ខែតុលា ឆ្នាំ ២០១៧ ស្តីពីការចេញផ្សាយធនប័ត្រប្រភេទ ១០០០ រៀល គំរូថ្មី ក្នុងព្រះរាជាណាចក្រកម្ពុជា ធនាគារជាតិនៃកម្ពុជា សូមប្រកាសផ្សាយជាសាធារណៈនូវលក្ខណៈសំគាល់នៃធនប័ត្រគំរូថ្មីនេះ មានដូចខាងក្រោម ៖

**ក- លក្ខណៈទូទៅ ៖**

- ទំហំធនប័ត្រ ៖ បណ្តោយ ១៤២ មម និងទទឹង ៦៨ មម
- ពណ៌ចម្បង គឺពណ៌ផ្ទៃមេឃ ពណ៌ខៀវ និងពណ៌លឿងទុំ ។

**ខ- ផ្ទៃខាងមុខនៃធនប័ត្រ ៖**

- **ផ្នែកកណ្តាល** ខាងស្តាំត្រូវបានរំលេចឡើងនូវព្រះឆាយាល័ក្ខណ៍នៃ **ព្រះបរមរតនកោដ្ឋ ព្រះបាទនរោត្តមសីហនុវរ្ម័ន** កាលពីព្រះអង្គទ្រង់គង់ប្រថាប់ក្នុងព្រះបរមរាជសម្បត្តិ ខាងឆ្វេងមានលេខ "១០០០" នៅពីលើគេ បន្ទាប់មកគឺជាហត្ថលេខារបស់ទេសាភិបាលនិងអគ្គបេឡា ព្រមទាំងរូបភាពតែងលំអយកតាមរូបក្បាច់ហោជាងនៃប្រាសាទក្នុងព្រះបរមរាជវាំង និងនៅពីក្រោមនោះមានលេខ-មាលាបោះពុម្ពដោយទឹកខ្មៅពណ៌ខ្មៅ រូបចម្លាក់នាគក្បាល ៥ នៅប្រាសាទបឹងមាលា និងអក្សរ "មួយពាន់រៀល" ព្រមទាំងអក្សរ "អ្នកក្លែងក្រដាសប្រាក់នឹងត្រូវផ្តន្ទាទោសតាមច្បាប់" នៅគែមខាងក្រោមនោះ ។

- **ផ្នែកខាងស្តាំ** ជ្រុងលើមានអក្សរ "ធនាគារជាតិនៃកម្ពុជា" ព្រមទាំងលេខ-មាលាបោះពុម្ពដោយទឹកខ្មៅពណ៌ក្រហម និងជ្រុងក្រោមមានលេខ "១០០០" ព្រមជាមួយលេខ "1000" នៅពីក្រោមនោះ ។

- **ផ្នែកខាងឆ្វេង** មានលេខ "1000" ព្រាលៗបោះពុម្ពតាមបន្ទាត់បញ្ឈរ ព្រមទាំងរូបភាពតែងលំអពណ៌ប្រាក់យកលំនាំតាមក្បាច់ចម្លាក់នៅប្រាសាទបន្ទាយស្រី បោះពុម្ពកាត់ទទឹងក្រដាស

ប្រាក់ពីលើដល់ក្រោម និងជ្រុងក្រោមមានគំនូសបន្ទាត់ខ្លីៗជាច្រើនបង្កើតឡើងដោយលេខ " ១០០០ " ដ៏តូចល្អិត ។

**គ- ផ្ទៃខាងខ្នងនៃធនប័ត្រ៖**

**- ផ្នែកកណ្តាល** ត្រូវបានរំលេចឡើងនូវរូបភាពព្រះទីនាំងទេវាវិនិច្ឆ័យមើលបញ្ឆិតពីជ្រុងមុខខាងឆ្វេង និងនៅពីក្រោមនោះ មានអក្សរ " មួយពាន់រៀល " ។

**- ផ្នែកខាងស្តាំ** ជ្រុងលើមានលេខ " 1000 " បោះពុម្ពតាមបន្ទាត់បញ្ឈរ នៅកណ្តាលជារូបចម្លាក់គ្រុឌឈរទ្រទ្រង់ប្រាសាទព្រះរាជដំណាក់ច័ន្ទ និងនៅជ្រុងក្រោមមានលេខ " ១០០០ " ។

**- ផ្នែកខាងឆ្វេង** ជ្រុងលើមានអក្សរ "ធនាគារជាតិនៃកម្ពុជា" អក្សរ " NATIONAL BANK OF CAMBODIA " និងលេខ " 2016 " នៅកណ្តាលមានរូបភាពព្រាលៗនៃរូបចម្លាក់ដាក់តាំងក្នុងព្រះបរមរាជវាំងនៃអតីតព្រះមហាក្សត្រព្រះបាទនរោត្តមទ្រង់គង់ប្រថាប់លើព្រះទីនាំងពាលីព្រមជាមួយក្បាច់លំអពណ៌ប្រាក់ផ្គុំឡើងដោយលេខ " ១០០០" ផ្ទុយគ្នា និងនៅជ្រុងក្រោមមានលេខ " ១០០០" ។

ចាប់ពីថ្ងៃចេញប្រកាសនេះតទៅ ធនប័ត្រប្រភេទ ១០០០ រៀល គំរូថ្មី ត្រូវបានដាក់ឲ្យធ្វើចរាចរទន្ទឹមគ្នាជាមួយនឹងធនប័ត្រជាតិប្រភេទផ្សេងៗទៀតដែលត្រូវបានចេញផ្សាយរួចមកហើយ។ សាធារណជនគ្រប់រូបត្រូវពិនិត្យ-សម្គាល់ធនប័ត្រគំរូថ្មីនេះឲ្យបានច្បាស់លាស់ ដើម្បីជៀសវាងការភ័ន្តច្រឡំ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៧

**ទេសាភិបាល**

ជា_ចាន់តូ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧.០១៧-៣២៤ ប្រ.ក

# ប្រកាស
# ស្តីពី
# លក្ខណៈសម្គាល់នៃធនប័ត្រ ប្រភេទ ៥០០០ រៀល គំរូថ្មី

***********

អនុលោមតាមអនុក្រឹត្យលេខ ១៨៤ អនក្រ.បក របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ ២០១៧ ស្តីពីការចេញផ្សាយធនប័ត្រប្រភេទ ៥០០០ រៀល គំរូថ្មី ក្នុងព្រះរាជាណាចក្រកម្ពុជា ធនាគារជាតិនៃកម្ពុជា សូមប្រកាសផ្សាយជាសាធារណៈ នូវលក្ខណៈសំគាល់នៃធនប័ត្រគំរូថ្មីនេះ មានដូចខាងក្រោម ៖

**ក- លក្ខណៈទូទៅ ៖**

- ទំហំធនប័ត្រ ៖ បណ្តោយ ១៤២ មម និងទទឹង ៦៨ មម
- ពណ៌ចម្បង គឺពណ៌ស្វាយ និងពណ៌ត្នោត ។

**ខ- ផ្ទៃខាងមុខនៃធនប័ត្រ ៖**

- **ផ្នែកកណ្តាល** ខាងស្តាំត្រូវបានរំលេចឡើងនូវព្រះឆាយាល័ក្ខណ៍នៃ **ព្រះបរមរតនកោដ្ឋ ព្រះបាទនរោត្តមសីហនុវរ្ម័ន** កាលពីព្រះអង្គនៅកំពុងបំពេញព្រះរាជបូជនីយកិច្ច ដឹកនាំចលនាតស៊ូទាមទារឯករាជ្យជាតិពីពួកអាណានិគមនិយមបារាំងសេស ខាងឆ្វេងមានលេខ "៥០០០" នៅពីលើគេ បន្ទាប់មកគឺជាហត្ថលេខារបស់ទេសាភិបាលនិងអគ្គបេឡា ព្រមទាំងរូបភាពតែងលំអយកតាមរូបក្បាច់ហោជាងនៃអគារតុលាការកំពូល និងនៅពីក្រោមនោះមានលេខ-មាលាបោះពុម្ពដោយទឹកខ្មៅពណ៌ខ្មៅ រូបចម្លាក់នាគក្បាល ៥ នៅវិមានឯករាជ្យ និងអក្សរ "ប្រាំពាន់រៀល" ព្រមទាំងអក្សរ "អ្នកក្លែងក្រដាសប្រាក់នឹងត្រូវផ្តន្ទាទោសតាមច្បាប់" នៅគែមខាងក្រោមនោះ ។

- **ផ្នែកខាងស្តាំ** ជ្រុងលើមានអក្សរ "ធនាគារជាតិនៃកម្ពុជា" ព្រមទាំងលេខ-មាលាបោះពុម្ពដោយទឹកខ្មៅពណ៌ក្រហម នៅកណ្តាលមានរូបភាពអង្គដៅចំណាំខាងមុខ ដែលមើលឆ្លុះឃើញលេខ "5000" និងជ្រុងក្រោមមានលេខ "៥០០០" ព្រមជាមួយលេខ "5000" នៅពីក្រោមនោះ ។

- **ផ្នែកខាងឆ្វេង** មានលេខ"5000" ព្រាលៗបោះពុម្ពតាមបន្ទាត់បញ្ឈរ ព្រមទាំងរូបភាពតែងលំអពណ៌ប្រាក់យកលំនាំតាមក្បាច់ចម្លាក់នៅប្រាសាទបន្ទាយស្រី បោះពុម្ពកាត់ទទឹងក្រដាស

ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ប្រាក់ពីលើដល់ក្រោម និងជ្រុងក្រោមមាននិមិត្តសញ្ញាសម្គាល់ប្រភេទប្រាក់សម្រាប់ជនពិការភ្នែក ព្រមទាំងមានគំនូសបន្ទាត់ខ្លីៗជាច្រើនបង្កើតឡើងដោយលេខ " ៥០០០ " ដ៏តូចល្អិត ។

**គ- ផ្ទៃខាងខ្នងនៃធនប័ត្រ៖**

- **ផ្នែកកណ្តាល** ត្រូវបានរំលេចឡើងនូវរូបភាពនាគក្បាល៩ នៅស្ពានបុរាណកំពង់ក្តី និងរូបតួស្ពានមើលបញ្ឆិតពីចំហៀងខាងស្តាំ នៅពីលើរូបស្ពានមានតែងលំអដោយក្បាច់ចម្លាក់នៅប្រាសាទបន្ទាយស្រី និងនៅពីក្រោមមានអក្សរ " ប្រាំពាន់រៀល " ។
- **ផ្នែកខាងស្តាំ** ជ្រុងលើមានលេខ"5000" បោះពុម្ពតាមបន្ទាត់បញ្ឈរ នៅកណ្តាលជារូបចម្លាក់នៅជញ្ជាំងប្រាសាទបាយ័ន និងនៅជ្រុងក្រោមមានលេខ " ៥០០០ " ។
- **ផ្នែកខាងឆ្វេង** ជ្រុងលើមានអក្សរ "ធនាគារជាតិនៃកម្ពុជា" អក្សរ " NATIONAL BANK OF CAMBODIA" និងលេខ " 2015 " នៅកណ្តាលមានរូបភាពព្រាលៗនៃរូបចម្លាក់ព្រះកេសទេវតានៅឯទ្វារជ័យខាងត្បូងនៃប្រាសាទបាយ័ន និងក្បាច់តែងលំអពណ៌ប្រាក់ផ្តុំឡើងដោយលេខ " ៥០០០ " ព្រមទាំងរូបភាពអង្គដៅចំណាំខាងខ្នងដែលមើលឆ្លុះឃើញលេខ " 5000 " ផ្កាប់ និងនៅជ្រុងក្រោមមានលេខ " ៥០០០ " ។

ចាប់ពីថ្ងៃចេញប្រកាសនេះតទៅ ធនប័ត្រប្រភេទ ៥០០០ រៀល គំរូថ្មី ត្រូវបានដាក់ឲ្យធ្វើចរាចរទន្ទឹមគ្នាជាមួយនឹងធនប័ត្រជាតិប្រភេទផ្សេងៗទៀតដែលត្រូវបានចេញផ្សាយរួចមកហើយ។ សាធារណជនគ្រប់រូបត្រូវពិនិត្យ-សម្គាល់ធនប័ត្រគំរូថ្មីនេះឲ្យបានច្បាស់លាស់ ដើម្បីជៀសវាងការភ័ន្តច្រឡំ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៧

**ទេសាភិបាល**

ជា_ចាន់តូ